**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ ៖ ៣១១៧ ក.ប/ប្រក

*រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៣*

# ប្រកាស

## ស្តីពី

## ការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករ-និយោជិត ផ្នែកវាយនភ័ណ្ឌ កាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើង

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ ១.-**

ត្រូវបានដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករ-និយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើងពី ៨០ (ប៉ែតសិប) ដុល្លារសហរដ្ឋអាមេរិក ទៅ ១០០ (មួយរយ) ដុល្លារសហរដ្ឋអាមេរិក ក្នុង ០១ ខែ សម្រាប់ឆ្នាំ២០១៤ បន្ថែមលើប្រាក់អត្ថប្រយោជន៍ផ្សេងៗទៀតដែលមានស្រាប់ ។

ចំនួនទឹកប្រាក់ដែលបានដំឡើងខាងលើនេះ ត្រូវបន្ថែមជូនកម្មករ-និយោជិតគ្រប់ៗគ្នាលើប្រាក់ឈ្នួលដែលកំពុងទទួលបាន។

**ប្រការ ២.-**

ប្រាក់ឈ្នួលអប្បបរមាដូចបានកំណត់ក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តចាប់ពីថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០១៤ តទៅ។

**ប្រការ ៣.-**

បង្កើតក្រុមការងារ ដើម្បីធ្វើការសិក្សាអំពីការដំឡើងប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករ-និយោជិត ផ្នែកវាយនភ័ណ្ឌ កាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើង សម្រាប់ពេលខាងមុខជាបន្តទៀត។

សមាសភាពនៃក្រុមការងារនេះ ត្រូវកំណត់ដោយសេចក្ដីសម្រេចដោយឡែក។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គាធិការ គណៈកម្មការប្រឹក្សាការងារ គ្រប់អង្គភាពក្រោមឱវាទក្រសួង ព្រមទាំងនិយោជកផ្នែកវាយនភ័ណ្ឌ កាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើង ត្រូវអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ: ០០៩/១៨ ក.ប/សរណន

# សេចក្តីណែនាំ
## ការអនុវត្តប្រកាសលេខ ៣១៧ ក.ប/ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិត ផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង និងការផ្តល់អត្ថប្រយោជន៍ផ្សេងៗ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបដល់អង្គការសហជីពគ្រប់ថ្នាក់ សមាគមនិយោជក កម្មករនិយោជិត និងនិយោជកនៃរោងចក្រ សហគ្រាស គ្រឹះស្ថាន ផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងទាំងអស់ ត្រូវអនុវត្តតាមសេចក្តីណែនាំដូចខាងក្រោម៖

I.**ការផ្តល់ប្រាក់ឈ្នួលអប្បបរមា**

១-កំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតសាកល្បង ចាប់ពី ១ ខែ ទៅ ៣ ខែ ចំនួន ៩៥ (កៅសិបប្រាំ) ដុល្លារក្នុងមួយខែ (ប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្ន ៧៥ ដុល្លារបូកប្រាក់ដំឡើង ចំនួន ២០ ដុល្លារ ស្មើនឹង ៩៥ ដុល្លារ)។ ចប់រយៈពេលសាកល្បង កម្មករនិយោជិតពេញសិទ្ធិត្រូវទទួលបានប្រាក់ឈ្នួលអប្បបរមាចំនួន ១០០ (មួយរយ) ដុល្លារក្នុងមួយខែ (ប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្ន ៨០ ដុល្លារបូកប្រាក់ដំឡើងចំនួន ២០ ដុល្លារ ស្មើនឹង ១០០ ដុល្លារ)។

២-ចំពោះកម្មករនិយោជិតដែលទទួលប្រាក់ឈ្នួលគិតតាមបរិមាណផលិតផល(ដេរសុីបុង) ត្រូវទទួលបានប្រាក់ឈ្នួលតាមទិន្នផលជាក់ស្តែងដែលធ្វើបាន។ បើទិន្នផលការងារទទួលបាននោះលើសពីចំនួនប្រាក់ឈ្នួលដែលមានចែងក្នុងចំណុចទី១ខាងលើ ត្រូវទទួលតាមការលើសនោះ។ ប្រសិនបើទាបជាង និយោជកត្រូវបន្ថែមឱ្យគ្រប់ចំនួន ៩៥ (កៅសិបប្រាំ) ដុល្លារក្នុងមួយខែ សម្រាប់

កម្មករនិយោជិតធ្វើការសាកល្បង និងចំនួន ១០០ (មួយរយ) ដុល្លារក្នុងមួយខែ សម្រាប់កម្មករនិយោជិតពេញសិទ្ធិ។

៣-ចំនួនទឹកប្រាក់ដែលត្រូវបានដំឡើងចំនួន ២០ (ម្ភៃ) ដុល្លារ ត្រូវបន្ថែមជូនកម្មករនិយោជិតគ្រប់ៗគ្នា លើប្រាក់ឈ្នួលដែលកំពុងទទួលបាន។

៤-ការផ្តល់ប្រាក់ឈ្នួលអប្បបរមា និងការដំឡើងប្រាក់ឈ្នួលដូចមានចែងក្នុងចំណុចទី១ ទី២ និងទី៣ ខាងលើ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៤ តទៅ។

II. **ការផ្តល់អត្ថប្រយោជន៍ផ្សេងៗដែលធ្លាប់បានអនុវត្តកន្លងមក**

១-ផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ៧ (ប្រាំពីរ) ដុល្លារ ក្នុងមួយខែ។

ចំពោះកម្មករនិយោជិតណាដែលនិយោជកបានផ្តល់មធ្យោបាយធ្វើដំណើរ ឬផ្តល់កន្លែងស្នាក់នៅ គឺមិនត្រូវទទួលបាននូវប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅនេះទេ។ បើនិយោជកណាបានផ្តល់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅល្អប្រសើរជាងការកំណត់នេះ ត្រូវរក្សានៅដដែល។

២-កម្មករនិយោជិត ដែលបានមកធ្វើការទៀងទាត់តាមចំនួនថ្ងៃនៃថ្ងៃធ្វើការក្នុងខែនីមួយៗ ដោយគ្មានអវត្តមាន ត្រូវទទួលបានប្រាក់រង្វាន់យ៉ាងតិចចំនួន ១០ (ដប់) ដុល្លារក្នុងមួយខែ។

ចំពោះរោងចក្រ សហគ្រាស គ្រឹះស្ថានណាដែលបានផ្តល់ប្រាក់រង្វាន់លើសពីការកំណត់នេះត្រូវរក្សាប្រាក់រង្វាន់ដែលឱ្យលើសនោះនៅដដែល។

៣-កម្មករនិយោជិតដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង តាមសំណូមពររបស់និយោជកត្រូវទទួលបានប្រាក់ថ្លៃបាយចំនួន ២០០០ (ពីរពាន់) រៀលក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់ជូនបាយមួយពេលដោយឥតគិតថ្លៃ។

៤-ប្រាក់រង្វាន់អតីតភាពការងារ

ក-កម្មករនិយោជិតដែលបានធ្វើការនៅក្នុងរោងចក្រ សហគ្រាស គ្រឹះស្ថានណាមួយលើសពីមួយឆ្នាំឡើងទៅ ត្រូវទទួលបានប្រាក់រង្វាន់អតីតភាពការងារ ដូចមាននៅក្នុងតារាងខាងក្រោមនេះ៖

| អតីតភាពការងារគិតជាឆ្នាំ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ |
|---|---|---|---|---|---|---|---|---|---|---|---|
| ចំនួនទឹកប្រាក់ទទួលបានក្នុងមួយខែគិតជាដុល្លារ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ |

ខ-កម្មករនិយោជិតដែលមានអតីតភាពការងារនៅឆ្នាំណា ត្រូវទទួលបានប្រាក់រង្វាន់អតីតភាពការងារនៅឆ្នាំនោះ (ដូចតារាងខាងលើ) លើកលែងតែកម្មករនិយោជិតដែលមានអតីតភាពការងារលើសពី ១១ ឆ្នាំឡើងទៅ ត្រូវទទួលបានប្រាក់រង្វាន់អតីតភាពការងារនៅក្នុងឆ្នាំទី១១ គឺចំនួន ១១ (ដប់មួយ) ថ្ងៃក្នុងមួយខែ ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា អង្គការសហជីពគ្រប់ថ្នាក់ សមាគមនិយោជក កម្មករនិយោជិត និងនិយោជកនៃរោងចក្រ សហគ្រាស គ្រឹះស្ថាន ផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងទាំងអស់ នឹងអនុវត្តតាមសេចក្តីណែនាំនេះបានល្អប្រសើរ និងធានាបាននូវប្រសិទ្ធិភាពខ្ពស់។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ [illegible] ឆ្នាំ២០១៤

ជ.រដ្ឋមន្ត្រី

អ៊ិត សំហេង

**កន្លែងទទួល:**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
-គ្រប់សមាគមនិយោជក
-គ្រប់សហព័ន្ធសហជីព
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ